**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣០២ សហវ.ពស.

# ប្រកាស

## ស្តីពី

## ការអនុវត្តន៍អាករលើតម្លៃបន្ថែម លើការនាំចូល និងការផ្គត់ផ្គង់ ទំនិញមួយចំនួន

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០១ លើលិខិតលេខ ១៤៩៤ សហវ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**<u>សម្រេច</u> :**

**ប្រការ ១ .-** អាករលើតម្លៃបន្ថែម លើការនាំចូល និងការផ្គត់ផ្គង់ ទំនិញមួយចំនួនសំរាប់ទិសដៅកសិកម្មដូចខាងក្រោមនេះ ត្រូវបានរដ្ឋទទួលបន្ទុក :

ក- ជីគ្រប់ប្រភេទ រួមមាន ជីសំរាប់ប្រើក្នុងវិស័យកសិកម្មគ្រប់មុខដំណាំដែលផ្សំដោយជាតិគីមី ជាតិសរីរាង្គ និងរ៉ែធម្មជាតិ ។

Collection by VCAT Professional Consultant

ខ- ពូជដំណាំគ្រប់ប្រភេទ រួមមាន :

១- គ្រាប់ពូជដំណាំគ្រប់ប្រភេទ

២- បំណែកពូជដំណាំគ្រប់ប្រភេទប្រើសំរាប់ការដាំដុះជា ដើម មើម ខ្នែង មែកសាក មែកផ្សាំ វល្លិ ។ល។

គ- បសុឱសថ រួមមាន ឱសថគ្រប់ប្រភេទប្រើប្រាស់តែលើសត្វគ្រប់ប្រភេទ សំរាប់ការទ្រទ្រង់សុខភាព ព្យាបាល ការពារ និងបង្កើន ផលិតភាពរបស់សត្វ ។

ឃ- ចំណីសត្វ និងចំណីបន្ថែម រួមមាន :

១- ចំណីសត្វគ្រប់ប្រភេទសំរាប់ការទ្រទ្រង់ការលូតលាស់របស់សរីរាង្គសត្វ

២- ចំណីបន្ថែមគ្រប់ប្រភេទ វីតាមីន ឬអង្គធាតុរ៉ែផ្សេងៗទៀត សំរាប់ប្រើប្រាស់បន្ថែមលើចំណីសត្វ ។

ង- ពូជសត្វគ្រប់ប្រភេទ រួមមាន :

១- ពូជសត្វស្រុកគ្រប់ប្រភេទ

២- ពូជសត្វព្រៃគ្រប់ប្រភេទ ។

ច- គ្រឿងយន្ត និងឧបករណ៍កសិកម្មប្រភេទ :

១- គោយន្តភ្ជួរ រាស់ និងបន្ទាស់សំរាប់គ្រួសារ

២- ម៉ាស៊ីនកិនចំណីសត្វ

៣- ឧបករណ៍បណ្តុះគ្រាប់ពូជ ឬ ភ្ញាស់ស៊ុតសត្វ

៤- តួបូមទឹកនៃម៉ាស៊ីនបូមទឹក ។

**ប្រការ ២.-** អាករលើតម្លៃបន្ថែមលើទំនិញដូចមានចែងក្នុងប្រការ ១ ខាងលើ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រា បូកសរុបជាចំណូលនៃថវិកាប្រចាំខែ ហើយត្រូវបានកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ "ជំពូក ៣០" ។

**ប្រការ ៣.-** អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច និងប្រធាននាយកដ្ឋានដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០១

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ។

Collection by VCAT Professional Consultant